# ១៥

# ត្រូវចេះធ្វើបុណ្យទើបបានបុណ្យច្រើន

*ការធ្វើបុណ្យ អាចចែកជាបីពេល គឺ ខណៈពេលមុនធ្វើ ខណៈពេលកំពុងធ្វើ និង ខណៈពេលធ្វើរួចហើយ ។ ដើម្បីបានបុណ្យច្រើន ត្រូវរបស់ទ្រព្យដែលយកមកធ្វើបុណ្យ នោះបានមកប្រកបដោយធម៌ ព្រះសង្ឃ ឬ លោកអ្នកដែលទទួលចតុបច្ច័យពីអ្នកធ្វើ បុណ្យនោះ ជាអ្នកមានសីល ហើយអ្នកធ្វើបុណ្យនោះទៀតគប្បីមានចិត្ត សទ្ធា ជ្រះថ្លា សប្បាយរីករាយ ទាំងបីខណៈ ។ តាមធម្មតា យើងច្រើនមានចិត្ត សទ្ធាជ្រះថ្លា សប្បាយរីករាយតែនៅពេលមុនធ្វើបុណ្យ ហើយដល់ពេលធ្វើបុណ្យ ក៏ជួបនឹងឧបសគ្គ ផ្សេងៗដែលពុំបានគ្រោងទុកជាមុន ដោយភ្លេចខ្លួនក៏ទៅជាខឹងនឹងភ្ញៀវក៏មាន ហើយ ដល់ធ្វើបុណ្យចប់ហើយ ជួនកាលអស់ប្រាក់កាសច្រើន ក៏មានបញ្ហាក្នុងគ្រួសារ ។ ខ្ញុំលើកតែការមិនស្រុះស្រួលនេះ មិនមែនបានន័យថា មានតែរបៀបនេះគ្រប់តែអ្នកដើម បុណ្យនោះទេ។ ខ្ញុំគ្រាន់តែចង់រំលឹកលោកអ្នកកុំឲ្យភ្លេចខ្លួន ខ្វាចកំពប់បុណ្យ ។ ម្យ៉ាងទៀត កាលណាយើងធ្វើអំពើជាកុសលណាមួយ យើងគង់តែនឹងបានផលពីអំ ពើនោះជាមិនខាន ដូច្នេះមិនចាំបាច់ ប្រាថ្នាថា សុំឲ្យបានសម្បត្តិព្រះរាជា ឬ សម្បត្តិសួគ៌ នោះឡើយ។ ព្រោះការប្រាថ្នានូវសម្បត្តិទាំងឡាយនេះ នាំចិត្តយើងឲ្យកើតលោភ ដែល ជា **អកុសលចិត្ត** ។*

*បើនិយាយតាមភាសាធម៌ <u>មុនពេលធ្វើបុណ្យ</u> បុគ្គល ត្រូវតែយល់ឲ្យច្បាស់អំពី អានិសង្ស នៃបុណ្យនោះ ហើយគួរត្រេកអរជ្រះថ្លា និងមានឆន្ទៈប្រកបដោយសទ្ធា ក្នុងការបំពេញ បុណ្យនោះ។ ចេតនា (អំពើ) នេះហៅថា បុព្វ ចេតនា ។*

ខណៈពេលកំពុងធ្វើបុណ្យ យើងត្រូវតែសប្បាយចិត្តជ្រះថ្លា ចំពោះអំពើល្អដែល
យើងកំពុងតែធ្វើនេះ ដោយដឹងថាអំពើល្អនឹងនាំមកនូវសេចក្តីសុខ ។ ចេតនានេះ
ឈ្មោះថា មុញ្ចន ចេតនា ។

បន្ទាប់ពីបានបំពេញកុសលហើយ យើងត្រូវតែរីករាយជ្រះថ្លា ចំពោះអំពើល្អដែលយើង
បានសាងហើយនោះ គឺ រាល់ពេលដែលយើងនឹកដល់អំពើល្អនោះ យើងតែងតែរីករាយ
សប្បាយចិត្ត ។ ចេតនានេះឈ្មោះថា អបរាបរ ចេតនា ។

បុណ្យ ដែលប្រកបដោយចេតនាទាំងបីយ៉ាងនេះហើយ ហៅថា បណីត ទាន និង
ទង្វើនេះ ហៅថា បណីត កុសលកម្ម។ បុណ្យកុសល ដែលប្រាសចាកចេតនាទាំងបីនេះ
ហៅថា ហីន ទាន និងទង្វើ ហៅថា ហីន កុសលកម្ម ។

បណីត កុសលកម្ម ឲ្យផលប្រសើរជាង ហីន កុសលកម្ម ។ ដូច្នេះ ទោះបុគ្គលពីររូប
បរិច្ចាគ ទានដូចគ្នាក៏ពិតមែន តែផលដែលពួកគេទទួលបាន គឺមិនដូចគ្នានោះទេ ។
អ្នកដែលបរិច្ចាគដោយសទ្ធាជ្រះថ្លា ប្រកបដោយចេតនាជាកុសល រមែងទទួលបាន
បណីតកុសលកម្ម គឺបានផលប្រសើរជាងអ្នកឯទៀត ៗ។

ដូច្នេះ បុគ្គលគួរបំពេញអំពើល្អប្រកបដោយ **បញ្ញា**យល់ច្បាស់ពីកម្ម និងផលរបស់កម្ម
និងប្រកបដោយ កុសលចេតនាទាំងបីយ៉ាង ដូចបានរៀបរាប់មកខាងលើនេះស្រាប់ ។